# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា នឹង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



ឆ្នាំទី២ — កុម្ភៈ លេខ ២

ព.ស. ២៤៩៣ - គ.ស. ១៩៥១

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ **ឈឹម - ក្រសេម**

សំណាក់ការ លេខ ៣៥ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង

ទំព័រ

វិចារណកថា . . . . . . . . . . . . . . . . . . . . . . . . . . . . ៤១

សមណភាព . . . . . . . . . . . . . ហប - ពិន . . . . . . . . . . ៤៣

អបរិហានិយធម្មសូត្រ (ត - ចប់) . . . . . ព្រះញាណកោសលញាណ - ឈឹម ៥៤

ប្រវត្តិឧកញ៉ាវង្សាសារពេជ្រ នង . . . . . ឈឹម - ក្រសេម . . . . . . . . ៥៧

ប្រវត្តិអក្សរ . . . . . . . . . . . . . . ឈឹម - ក្រសេម . . . . . . . . ៦០

បញ្ចតន្ត្រៈ (តមក) សេចក្តីប្រែបស់ . . . . ភិក្ខុញ៉ុគ - ខាត់ . . . . . . . . ៦៩

សេចក្តីថ្លែងការ . . . . . . . . . . . . . . . . . . . . . . . . . ៧៥

---

ដំឡៃជាវប្រចាំឆ្នាំ ១០០ រៀល

---

អ្នកអានទាំងឡាយ។ សូមអញ្ជើញចុះឈ្មោះជាវ។

នឹងបបួលញាតិមិត្តជួយជាវ។

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ

# វិចារណកថា

ការសំអាតរូបកាយឲ្យស្អាតផូរផង់ហើយតាក់តែងស្រោបដណ្ដប់ ដោយសំលៀកបំពាក់ថ្មីថ្មោងសមរម្យចុះបែបតាមកាលសម័យ ឈ្មោះថា ថ្កុំថ្កើងថ្លៃថ្នូរមួយចំណែកហើយ, ប៉ុន្តែការសំអាតកាយនេះ មិនអាចញុំាងសន្តិភាពឲ្យតាំងនៅជាស្ថាពរ ក្នុងគ្រួសារ ក្នុងសង្គម ក្នុងលោកបានឡើយ ។ សេចក្ដីសំខាន់ក្នុងខនេះ គឺត្រូវមានការសំអាតចិត្តអែបជាមួយផង ទើបជាកិច្ចប្រសើរបំផុត ។

ឯពិធីសំអាតចិត្តនោះមានច្រើនប្រការ, តែបើពោលដោយរួបរួមមានត្រឹមតែ ៣ យ៉ាងប៉ុណ្ណោះ គឺទាន, សីល, ភាវនា ។ ទានជាគ្រឿងបន្ថយនូវលោភៈ ទុកជាប្រដាប់សំអាតចិត្តថ្នាក់ទី ១ ។ សីលជាគ្រឿងកំរាបនូវទោសៈ ទុកជាប្រដាប់សំអាតចិត្តទី ២ ។ ភាវនា ជាគ្រឿងកំចាត់បង់នូវមោហៈ ទុកជាប្រដាប់សំអាតចិត្តទី ៣ ។ មានពុទ្ធបរិស័ទជាច្រើនយល់ថា "ភាវនាតែមួយទេដែលជាគ្រឿងសំអាតចិត្តឲ្យផូរផង់", គេមិនយល់ថា ទាននឹងសីលជាប្រដាប់សម្រាប់ដុសខាត់ចិត្តផងទេ, ម៉្លោះហើយចិត្តអ្នកទាំងនោះ ដែលបានខំប្រឹងឲ្យទានរក្សាសីលជានិច្ចរាល់ថ្ងៃ ក៏នៅតែជាចិត្តល្មោភលោភលន់ហួសហេតុនឹងឃោរឃៅទុរចេរប្រឡោតទទឹងទិសដដែល ឥតទោរទន់ទៅរកសេចក្ដីស្ងប់ស្ងាត់សោះ សមដូចពាក្យគេថា "បុណ្យតែធ្វើឈើតែកាប់" ។ ចិត្តទុកជាភាជន៍សម្រាប់

ទ្រទ្រង់នូវផលរបស់ទាន-សីល ដែលយើងបានសន្សំមក កាលបើចិត្ត
ធុះធ្លាយហើយតើផលបុណ្យនោះនឹងតាំងនៅលើអ្វី? ។

សព្វថ្ងៃនេះ គេច្រើនមិនសូវរវល់ចំពោះការអប់រំចិត្តទេ, សូម្បី អ្នកដែលធ្វើទានរក្សាសីលស្រាប់ហើយនោះ ក៏តែងបណ្ដោះបណ្ដែត ទៅលើសេចក្ដីប្រហែសធ្វេសថា ចាំដល់ខ្លួនចាស់សឹមធ្វើការនាសម្រិត សម្រាំងចិត្តផ្ដាច់ព្រ័ត្រតែម្ដង ។ អ្នកខ្លះចាំៗទៅ មិនបានផ្ដាច់ព្រ័ត្រចិត្ត, ទៅជាមច្ចុមកផ្ដាច់ព្រ័ត្រជីវិតខ្លួនឯងខានចាស់ទៅវិញក៏មាន ។ នេះមក ពីយល់ថា ការធ្វើទានរក្សាសីលនឹងការទូន្មានចិត្តនៅឆ្ងាយដោយឡែក ពីគ្នា ។ តាមសេចក្ដីពិត, គប្បីយល់ជាក់ប្រាកដថា ការប្រដៅពត់ចិត្ត ឲ្យបានបែបបទតែងមាននៅហូរហែជាមួយគ្នា តាំងពីក្នុងទាន សីលខាង ដើមទៅ, មិនមែនទៅតួនសម្ងំនៅក្នុងការនាខាងចុងឯណោះតែម្យ៉ាងទេ គឺយើងគប្បីផ្សាំងចិត្តសន្សំៗ តាំងពីថ្នាក់ទី ១ ទី ២ ដំបូងទៅ ដើម្បីឲ្យ ចិត្តនោះស្ងប់ស្ងាត់ពបសាបណ្ដើរៗ កុំឲ្យក្រាក់ផ្អើលដោយលោភៈ នឹង ទោសៈពេក, តទៅទើបយើងរុញចិត្តនោះបញ្ចូលក្នុងនឹមគឺការនាថ្នាក់ទី ៣ ក្រោយបន្តស់ ៗ ធ្វើដូច្នេះ, ជាទំនងណាយក្នុងការសំអាតចិត្ត ហើយ ដល់ទៅក្នុងទីបំផុត សទ្ធិភាពគង់នឹងអាចតាំងនៅបានយ៉ាងឋិតថេរក្នុងគ្រួ- សា ក្នុងសង្គម ក្នុងលោកពុំខាន ដោយចិត្តយើងស្អុតបូតមានមេត្តា ប្រាសចាកឫសអកុសលទាំង ៣ គឺលោភៈ ទោសៈ មោហៈ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុ ជាភិក្ខុនី ជាឧបាសក ជាឧបាសិកា ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន នឹងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

## សមណភាព

មនុស្សក្នុងសាកលលោក នឹងនៅតាមទំនើងខ្លួនម្នាក់ៗមិនបាន លុះតែពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកទើបបាន, ព្រោះហេតុនេះ ទើបកើតមានជាពួកជាក្រុមឡើង ។ កាលបើកើតជាពួកជាក្រុមហើយ ក៏រួមគ្នាជាជាតិ ។ កាលបើរួមគ្នាជាជាតិហើយ ត្រូវតែមានធម៌ជាគ្រឿងបង្ហាញផ្លូវប្រតិបត្តិឲ្យដឹងថា ដូចម្តេចជាអំពើគួរធ្វើ ដូចម្តេចជាអំពើគួរលះបង់ ដើម្បីឲ្យកើតសេចក្តីសុខ សេចក្តីចម្រើនដល់ពួកដល់ក្រុមនោះៗ; ពាក្យប្រដៅដូច្នោះ ហៅថា "សាសនា" ។ សាសនាកើតឡើងដោយមានហេតុដូចពោលមកនេះ ។

ក្នុងសាកលលោក តាំងពីសម័យបុរាណ ដរាបដល់មកសម័យបច្ចុប្បន្ន មានសាសនាច្រើនជាអនេក, សាសនាធំៗដែលមានសាសនិក-

ជនកាន់តាមច្រើនៗ មានសាសនាព្រាហ្មណ៍ សាសនាព្រះពុទ្ធ សាសនាឥស្លាម និងសាសនាគ្រិស្តជាដើម ។ សាសនាទាំងនោះ មានដំណើរពាក្យប្រដៅប្រហែលគ្នាក៏មាន ឃ្លាតឆ្ងាយដាច់ស្រយាលពីគ្នាណាស់ក៏មាន ។ ពាក្យប្រដៅក្នុងសាសនាដទៃក្រៅពីព្រះពុទ្ធសាសនា មិនបាននាំមកសំដែងក្នុងទីនេះទេ, នាំយកតែពាក្យប្រដៅក្នុងព្រះពុទ្ធសាសនាមួយ ដែលជាសាសនាប្រដៅឲ្យមានសមណភាពមកសំដែងដោយសង្ខេបដូចតទៅនេះ :

ពាក្យថា "សមណភាព (ប្រែថា) ភាពនៃបុគ្គលជាអ្នកស្ងប់" គឺស្ងប់កាយ ស្ងប់វាចា ស្ងប់ចិត្ត ។ ការសង្រួមប្រយ័ត្នមិនឲ្យអំពើអាក្រក់ចេញមកប្រាកដតាមកាយទ្វារ គឺមិនសម្លាប់សត្វ មិនលួចទ្រព្យគេ, មិនប្រព្រឹត្តខុសក្នុងកាម ហៅថា "ស្ងប់កាយ" ។ ការសង្រួមប្រយ័ត្នមិនឲ្យសំដីអាក្រក់ចេញមកប្រាកដតាមវចីទ្វារ គឺមិននិយាយកុហក, មិននិយាយញុះញង់, មិននិយាយទ្រគោះ, មិននិយាយឥតប្រយោជន៍ ហៅថា "ស្ងប់វាចា" ។ ការសង្រួមប្រយ័ត្នមិនឲ្យគំនិតអាក្រក់កម្រើកឡើងប្រាកដក្នុងមនោទ្វារ គឺមិនគិតរំពៃចង់បានទ្រព្យគេ, មិនគិតគុំគួន, មិនយល់ខុស ហៅថា "ស្ងប់ចិត្ត" ។ បុគ្គលដែលស្ងប់កាយ វាចា ចិត្ត ដូចពោលមកនេះ ហៅថា "អ្នកស្ងប់ចាកបាប" ។

ការសម្លាប់សត្វ, ការលួចទ្រព្យគេ, ការប្រព្រឹត្តខុសក្នុងកាម ហៅថា "អំពើអាក្រក់ក្នុងកាយ" ។ ការនិយាយកុហក, ការនិយាយញុះញង់, ការនិយាយទ្រគោះ, ការនិយាយឥតប្រយោជន៍ ហៅថា "អំពើអាក្រក់ក្នុងវាចា" ។ ការគិតរំពៃចង់បានទ្រព្យគេ, ការគិតគុំគួន, ការយល់ខុស ហៅថា "អំពើអាក្រក់ក្នុងចិត្ត" ។ បុគ្គលដែលប្រព្រឹត្តអំពើអាក្រក់ក្នុងកាយ វាចា ចិត្ត ហៅថា "អ្នកធ្វើបាប" ។

បណ្ដាទ្វារទាំង ៣ គឺ កាយ វាចា ចិត្តនោះ ចិត្តជាធម្មជាតនាំបណ្ដាលឲ្យធ្វើបាបមុនគេបង្អស់, កាយ នឹងវាចា បើមិនមានចិត្តផ្ដើមឡើងជាមុនទេ ក៏ធ្វើបាបមិនកើត ព្រោះកាយប្រៀបដូចរូបយន្ត ចិត្តដូចមនុស្សអ្នកទាញខ្សែរូបយន្តឲ្យកក្រើក, រូបយន្ត បើមិនមានមនុស្សទាញខ្សែក៏មិនអាចកក្រើកបាន យ៉ាងណាមិញ, កាយ បើមិនមានចិត្តនាំបណ្ដាលទេ ក៏កក្រើកមិនបាន យ៉ាងនោះដែរ ។ បាបដែលកើតក្នុងចិត្តមានច្រើនបំពូក តូចក៏មាន ធំក៏មាន ។

ព្រះពុទ្ធសាសនា ប្រដៅពុទ្ធសាសនិកជនមិនឲ្យធ្វើបាបគ្រប់បំពូកទាំងតូច ទាំងធំ មានឃាត់មិនឲ្យបៀតបៀនសត្វ សម្លាប់សត្វជាដើម ឲ្យចម្រើនមេត្តាចិត្ត អាណិតអាសូរទូទៅទាំងសត្វនឹងមនុស្សទាំងពួង គ្រប់ទិសតំបន់ ឲ្យនឹករំពឹងប្រៀបធៀបខ្លួនឯងនឹងអ្នកដទៃថា "អាត្មាអញចង់បានសេចក្ដីសុខ ស្រឡាញ់ជីវិតនឹងរាងកាយរបស់អាត្មាអញយ៉ាងណា,

អ្នកដទៃក៏យ៉ាងនោះដែរ", មេត្តាចិត្តនេះជាសេចក្ដីល្អក្រៃពេក ។ អ្នកដែលមិនសម្លាប់គេ ព្រមទាំងបានចម្រើនមេត្តាចិត្តថែមទៀត. ហៅថា "អ្នកឋិតនៅក្នុងគន្លងធម៌ដ៏ល្អ" ជាទីគាប់ចិត្តរបស់មនុស្សនិងសត្វទូទៅ ព្រោះមនុស្សនិងសត្វក្នុងសាកលលោក រមែងស្អប់ទុក្ខ ស្រឡាញ់សុខ, ស្អប់ស្លាប់ ស្រឡាញ់រស់, ស្អប់អាក្រក់ ស្រឡាញ់ល្អ, ស្អប់ក្រ ស្រឡាញ់មាន ជាធម្មតា, រមែងហួងហែងរក្សានូវជីវិតរបស់ខ្លួនក្រៃពេក. មិនចង់ឲ្យអ្នកដទៃមកធ្វើឲ្យអន្តរាយជីវិតនោះឡើយ ។ ពាក្យដែលពោលមកនេះ ជាពាក្យប្រដៅក្នុងព្រះពុទ្ធសាសនា, ព្រោះហេតុនោះព្រះពុទ្ធសាសនា ទើបបាននាមថាជាសាសនាល្អបំផុតក្នុងលោក ឥតមានសាសនាណាជាគូប្រៀបផ្ទឹមបាន ដោយមានធម៌ជាគោលសំខាន់យ៉ាងនេះជាដើម សម្រាប់ប្រដៅពុទ្ធបរិសទ្យឲ្យធ្វើសេចក្ដីទំនុកបម្រុងប្រយោជន៍ដ៏ធំទូលាយដល់សត្វ និងមនុស្សជាសាធារណៈ មិនរើសមុខ ទោះបីមនុស្ស ទោះបីសត្វ ក៏ចង់ឲ្យបានសេចក្ដីសុខស្មើមុខពល់គ្នា ។

មួយទៀត ព្រះពុទ្ធសាសនា ប្រដៅថា បើបុគ្គលណាមានចិត្តអាក្រក់ ឥតមេត្តាករុណា ហើយធ្វើអំពើអាក្រក់ដោយកាយឬវាចា មានសម្លាប់សត្វជាដើម តាមចិត្តដែលអាក្រក់នោះ វិបាកទុក្ខរមែងជាប់ជិតប្រកិតតាមបុគ្គលនោះ ក្នុងជាតិនេះ និងជាតិខាងមុខ ដូចកង់រទេះវិលជាប់តាមស្នាមជើងគោ គេចមិនរួចអំពីបាបកម្មនោះឡើយ ទុកជា

រត់ទៅជ្រកពួនក្នុងអាកាស ក្នុងសមុទ្រ ក្នុងចន្លោះភ្នំឯណាក្តី ឬទៅឋិតនៅក្នុងប្រទេសណាមួយក្តីឲ្យតែមានផែនដីសូម្បីប៉ុនចុងសក់ គឺមិនរួចដែរ, ទោះបីរត់ទៅពឹងព្រះពុទ្ធសុំអង្វរព្រះអង្គឲ្យទ្រង់ជួយឲ្យរួចបាបកម្មនោះ គឺមិនរួចឡើយ, លុះតែមិនធ្វើបាបដោយខ្លួនឯង ទើបមិនមានបាបចំពោះខ្លួន; ព្រោះហេតុនោះ បានជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា “បាបដែលបុគ្គលណាធ្វើដោយខ្លួនឯង បុគ្គលនោះត្រូវសៅហ្មងដោយខ្លួនឯង, បាបដែលបុគ្គលណាមិនធ្វើដោយខ្លួនឯង បុគ្គលនោះរមែងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធិនឹងមិនបរិសុទ្ធិស្រេចតែនឹងខ្លួនឯង អ្នកដទៃនឹងជួយធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបាន” ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកសំដែងប្រាប់ផ្លូវ បាប-បុណ្យ ប៉ុណ្ណោះ មិនមែនទទួលបាបបុណ្យជំនួសទេ ។

ព្រះពុទ្ធឱវាទនេះ ជាហេតុនាំពុទ្ធបរិសទ្យឲ្យមានចិត្តខ្លាចបាបនឹងជាហេតុនាំឲ្យស្រឡាញ់បុណ្យខំប្រឹងធ្វើកាយវាចាចិត្តឲ្យស្ងប់រម្ងាប់ចំពោះ ៗ ខ្លួន មិនឲ្យអាងអ្នកដទៃ ព្រោះហួសវិស័យនឹងអាងបាន ក្នុងការបរិសុទ្ធិនឹងមិនបរិសុទ្ធិនេះ ។

ពាក្យដែលប្រដៅមនុស្សឲ្យខ្លាចបាប ឲ្យមានចិត្តមេត្តាករុណាជាដើម ដើម្បីឲ្យមានកាយវាចាស្ងប់រម្ងាប់ដូចពោលមកនេះ ជាគោលនៃសេចក្តីល្អចំណែកមួយជាខាងដើមរបស់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាមានលំអ ៣ ចំណែក គឺលំអចំណែកដើម បានខាងសីល, លំអ

ចំណែកកណ្ដាល បានខាងសមាធិ, លំអចំណែកចុងបំផុត បានខាងបញ្ញា លំអទាំង ៣ ចំណែកនេះ ហៅថា "ត្រៃសិក្ខា" ។ កាលបើពុទ្ធសាវកបានសិក្សាកាន់តាមគោលត្រៃសិក្ខា គឺបានធ្វើកាយ វាចា ឲ្យរាបសាដោយការរក្សាសីល, បានដុសខាត់ចិត្តឲ្យផូរផង់ ដោយការចម្រើនសមាធិ បានពិចារណាធុះធ្លាយក្នុងសភាពធម៌តាមសេចក្ដីពិត ដោយការចម្រើនបញ្ញាចំពោះខ្លួនឯងហើយ រមែងមានសេចក្ដីបរិសុទ្ធិស្ងប់រម្ងាប់ចាកបាបខ្លួនឯង ជាបុគ្គលស្លូតសុភាពរាបសា ល្អគួរជាទីគោរពបូជារបស់មនុស្សនឹងទេវតាក្នុងលោក ។

ពុទ្ធសាវកដែលប្រតិបត្តិតាមព្រះឱវាទក្នុងព្រះពុទ្ធសាសនា មានកាយ វាចា ចិត្ត ស្ងប់រម្ងាប់ចាកបាបទាំងតូចទាំងធំ លោកហៅថា "សមណៈ" ប្រែថា "អ្នកស្ងប់" ។

សាសនាដែលប្រដៅមនុស្សឲ្យមានកាយវាចាចិត្ត ស្ងប់រម្ងាប់ចាកបាបទាំងតូចទាំងធំ ឲ្យមានសមណភាព ដរាបដល់ប្រដៅឲ្យបានសម្រេចព្រះនិព្វានជាទីបំផុត មានតែព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ, ក្រៅពីនេះមិនមានឡើយ ។

សេចក្ដីដែលពោលមកនេះ គាប់ដល់ពុទ្ធភាសិតគាថាដែលព្រះសក្យមុនីបរមគ្រូទ្រង់សំដែងប្រោសសុភទ្ទបរិព្វាជក ក្នុងវេលាទៀបទ្រង់បរិនិព្វានថា :

អាកាសេវ បទំ នត្ថិ  សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធាន មិញ្ជិតំ ។

ប្រែថា: សមណៈខាងក្រៅ មិនមាន, សង្ខារទាំងឡាយដែលទៀងមិនមាន, សេចក្ដីញាប់ញ័ររបស់ព្រះពុទ្ធទាំងឡាយ មិនមាន, ដូចស្នាមជើង មិនមានក្នុងអាកាស ។

ពុទ្ធភាសិតគាថានេះ ព្រះនរាសភ: បរមគ្រូទ្រង់សំដែងប្រៀបធៀបគតិលោកនឹងគតិធម៌ថា ស្នាមជើងមិនមានក្នុងអាកាស យ៉ាងណាមិញ, ក្រៅពីសាសនារបស់ព្រះអង្គ ក៏មិនមានសមណៈ យ៉ាងនោះដែរ, សមណៈមានតែក្នុងសាសនារបស់ព្រះអង្គមួយប៉ុណ្ណោះ គឺលុះតែបុគ្គលចូលមកធ្វើជាពុទ្ធសាវក ទទួលស្ដាប់តាមព្រះឱវាទរបស់ព្រះអង្គជាមុន ហើយនាំយកទៅប្រតិបត្តិដុសខាត់កាយ វាចា ចិត្ត របស់ខ្លួនឲ្យស្អាតឲ្យស្ងប់រម្ងាប់ចាកបាបជាខាងក្រោយ ទើបគួរហៅថា "សមណៈ" បាន ។

ពាក្យថា "សមណៈ" ក្នុងសំណៅពុទ្ធភាសិតនោះ សំដៅយកព្រះខីណាស្រពដែលចប់ព្រហ្មចរិយធម៌ អស់កិលេសាសវៈ បានដល់នូវសេចក្ដីស្ងប់យ៉ាងខ្ពស់បំផុត គឺព្រះនិព្វានដែលជាលោកុត្តរធម៌ ផុតវិស័យរបស់លោក ប្រសើរក្រៃលែងសេចក្ដីស្ងប់ទាំងឡាយ ។ តែន័យខ្លះ សំដៅយកព្រះអរិយបុគ្គល ៤ បំពូក គឺលោកអ្នកបានសម្រេចសោតៈបំពូក ១ សកទាគាមិ បំពូក ១ អនាគាមិ បំពូក ១ អរហត្តបំពូក ១ ។

មិនតែប៉ុណ្ណោះ សូម្បីភិក្ខុសាមណេរជាកល្យាណបុថុជ្ជនដែលជាអ្នកមានកាយ វាចា ចិត្ត ស្ងប់ស្ងៀមប្រាសចាកទោសនឹងការបៀតបៀនអ្នកដទៃហើយក្តី ជាអ្នកកំពុងតែប្រតិបត្តិតាមបដិបទា ដែលប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់កាយ វាចា ចិត្ត ក្តី ក៏បានឈ្មោះថាជា "សមណៈ" ដែរ ។ ឯបដិបទាជាគ្រឿងធ្វើបុគ្គលឲ្យជាសមណៈនោះ មានច្រើនប្រការ, តែបើពោលដោយរួបរួម មានតែ ៣ យ៉ាងហៅថា "ត្រៃសិក្ខា" គឺសីល សមាធិ បញ្ញា ។ សីលនោះ កាលបើចែកចេញជាប្រភេទ ក៏មានច្រើនប្រការ គឺសីល ៥ សីល ៨ សីល ១០ នឹងចតុប្បារិសុទ្ធិសីល ដែលមានបាតិមោក្ខសំវរសីល ២២៧ សិក្ខាបទជាដើម ។ សីលទាំងនេះ បើពោលដោយសរុប នៅតែ ២ ប្រការ គឺអាគារិកសីល (សីលរបស់អាគារិកជន) គឺឧបាសក ឧបាសិកា ១ អនាគារិកសីល (សីលរបស់អនាគារិកជន) គឺភិក្ខុសាមណេរ ១ ។ បើនិយាយដល់ផលប្រយោជន៍របស់សីលនោះៗ ដែលព្រះដ៏ទ្រង់យសជាបរមគ្រូទ្រង់បញ្ញត្តឡើង ក៏ដើម្បីឲ្យពុទ្ធសាសនិកជនអ្នកកាន់តាមពុទ្ធបញ្ញត្តនោះៗ មានកាយ វាចា ស្ងប់ស្ងៀមរាបសាជាថ្នាក់ៗ តាមភូមិភេទទាបខ្ពស់ជាងគ្នា ។

ព្រោះហេតុនេះ ភិក្ខុសាមណេរដែលបានឈ្មោះថា "សមណៈ" ក្នុងព្រះពុទ្ធសាសនាហើយ គប្បីជុសខាត់សំអាតសីលសិក្ខាបទតាមភូមិភេទរបស់ខ្លួន កុំឲ្យចិត្តសៅហ្មង ទើបសមនឹងឈ្មោះថា "សមណៈ" ដែលប្រែថា "អ្នកស្ងប់ចាកបាប" នោះឯង ។

ព្រះពុទ្ធសាសនារុងរឿងឬអាប់ឱន ដោយពួកពុទ្ធបរិសទ្យ គឺភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ប្រព្រឹត្តត្រូវឬខុសរបៀបបទបញ្ញត្តិនិងគោលធម៌របស់ព្រះពុទ្ធសាសនា, អ្នកដទៃមិនមែនពុទ្ធបរិសទ្យមិនអាចធ្វើព្រះពុទ្ធសាសនាឲ្យរុងរឿងឬអាប់ឱនទេ ។

ព្រះពុទ្ធសាសនារុងរឿង ដោយហេតុ ៥ យ៉ាង គឺ

១ – សក្កច្ចំ ធម្មំ សុណន្តិ = ភិក្ខុទាំងឡាយស្តាប់ធម៌ ដោយគោរព

២ – សក្កច្ចំ ធម្មំ បរិយាបុណន្តិ=ភិក្ខុទាំងឡាយរៀនធម៌ ដោយគោរព

៣ – សក្កច្ចំ ធម្មំ ធារេន្តិ = ភិក្ខុទាំងឡាយទ្រទ្រង់ធម៌ ដោយគោរព

៤ – សក្កច្ចំ ធតានំ អត្ថំ ឧបបរិក្ខន្តិ = ភិក្ខុទាំងឡាយ ពិចារណាសេចក្តីធម៌ដែលបានទ្រទ្រង់ហើយ ដោយគោរព ។

៥ – សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ= ភិក្ខុទាំងឡាយចេះដឹងបាលីនិងអដ្ឋកថាហើយ បានប្រតិបត្តិធម៌សមគួរដល់ធម៌ដោយគោរព ។

ព្រះពុទ្ធសាសនាសាបសូន្យ ក៏ដោយហេតុ ៥ យ៉ាងដែរ គ្រាន់តែផ្ទុយគ្នានឹងហេតុខាងរុងរឿងប៉ុណ្ណោះ គឺកាលបើភិក្ខុទាំងឡាយមិនស្តាប់, មិនរៀន, មិនទ្រទ្រង់, មិនពិចារណា, មិនប្រព្រឹត្តធម៌ ដោយគោរព, ឬស្តាប់ហើយ, រៀនហើយ តែមិនទ្រទ្រង់ គឺមិនកត់ចំណាំធម៌ឲ្យស្ទាត់ជំនាញក្តី, ឬកត់ចំណាំហើយ តែមិនពិចារណាបាលីនិងអដ្ឋកថា

ឲ្យផុះផ្លាយក្តី ឬក៏ពិចារណាផុះផ្លាយហើយ តែមិនកាន់ឲ្យត្រឹមត្រូវតាមច្បាប់ដែលបានរៀនមកនោះក្តី ព្រះពុទ្ធសាសនាក៏មិនរុងរឿងឡើយ ។

ភិក្ខុសាមណេរដែលបួសក្នុងសំណាក់ព្រះពុទ្ធសាសនាជាសាសនាដ៏ខ្ពង់ខ្ពស់ បានឈ្មោះថា "សមណៈ" ហើយ គួរតែលើកស្ទួយព្រះពុទ្ធសាសនាឲ្យផុសអណ្តែតត្រសែតឡើងនឹងគប្បីសំអាតកាយ វាចា ចិត្តរបស់ខ្លួន ឲ្យស្អាតផូរផង់ កុំឲ្យមានទោសមានអាបត្តិ ទើបសមគួរនឹងឈ្មោះថា "សមណៈ" ដ្បិតព្រះត្រៃលោកនាថទ្រង់ដាស់តឿនថា "ម្នាលភិក្ខុទាំងឡាយ! មហាជនតែងស្គាល់ឈ្មោះអ្នកទាំងឡាយថា "សមណៈ"; ចំណែកខាងអ្នកទាំងឡាយសោត កាលបើមានគេសួរថា "លោកជាអ្វី? អ្នកទាំងឡាយក៏ឆ្លើយប្តេជ្ញាខ្លួនថា "អាត្មាជាសមណៈដូច្នេះដែរ, កាលបើអ្នកទាំងឡាយមានឈ្មោះយ៉ាងនេះ នឹងប្តេជ្ញាខ្លួនយ៉ាងនេះហើយ ត្រូវដឹងខ្លួនថា "ធម៌ទាំងឡាយឯណាដែលធ្វើឲ្យជាសមណៈផង ធ្វើឲ្យជាព្រាហ្មណ៍ផង យើងទាំងឡាយនឹងសមាទានកាន់តាមធម៌ទាំងនោះ, ប្រព្រឹត្តយ៉ាងនេះ ទើបសមនឹងសេចក្តីប្តេជ្ញារបស់យើងទាំងឡាយដោយពិត ដូចពាក្យគេហៅមែន ។ មួយទៀត យើងទាំងឡាយបានបរិភោគចីវរ, បិណ្ឌបាត, សេនាសនៈ គិលានភេសជ្ជ-បរិក្ខារ របស់ទាយកទាំងឡាយឯណា អំពើបុណ្យកុសលរបស់ទាយកអម្បាលនោះមុខជាមានផលធំ មានអានិសង្សធំ ព្រោះអាស្រ័យយើង

ទាំងឡាយមិនខានឡើយ ។ មួយវិញទៀត ផ្នួសរបស់យើងទាំងឡាយ នឹងមិនឥតផលទេ ជាផ្នួសមានផល មានកម្រៃដោយពិត, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយត្រូវដឹងខ្លួនយ៉ាងនេះរាល់ៗ គ្នាចុះ កុំភ្លេចឡើយ" ។

កាលបើទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់សំដែងអំពីធម៌ដែលធ្វើមនុស្សឲ្យជាសមណៈតទៅ, ទ្រង់លើកយកហិរិ (សេចក្ដីខ្មាសបាប) ឱត្តប្បៈ (សេចក្ដីខ្លាចបាប) ឡើងជាប្រធាននៃធម៌ទាំងពួង ហើយទ្រង់សំដែងថាបរិសុទ្ធកាយសមាចារ (កាយសុចរិត ៣) បរិសុទ្ធវចីសមាចារ (វចីសុចរិត៤) បរិសុទ្ធមនោសមាចារ (មនោសុចរិត៣) បរិសុទ្ធសម្មាអាជីវៈ (ការចិញ្ចឹមជីវិតដោយផ្លូវបរិសុទ្ធ) ឥន្ទ្រិយសំវរៈ (ការសង្រួមឥន្ទ្រិយ ៦) ភោជនេ មត្តញ្ញុតា (ការដឹងប្រមាណក្នុងភោជន) ជាគរិយានុយោគ (សភាពជាបុគ្គលភ្ញាក់រលឹករឿយ ៗ មិនល្ងោកដេកច្រើនពេក) សតិសម្បជញ្ញៈ (សេចក្ដីរលឹកនឹងសេចក្ដីដឹងខ្លួនសព្វគ្រប់) ការអាស្រ័យសេនាសនៈដ៏ស្ងាត់, ការជម្រះចិត្តឲ្យប្រាសចាកនីវរណធម៌ហើយដម្កល់ខ្ជាប់ជាសមាធិ, ធ្វើបញ្ញាដែលឃើញច្បាស់នូវចតុរារិយសច្ចឲ្យកើតឡើង ។ ធម៌អម្បាលនេះ ជាធម៌របស់សមណៈ ហៅថា "សមណធម៌" ។ បុគ្គលដែលប្ដេជ្ញាខ្លួនថាជា "សមណៈ" ត្រូវតែមានធម៌ទាំងនេះក្នុងសន្ដាន ។

ឃុន ឧត្តមប្រជា ចាប-ពិន

# អបរិហានិយធម្មសូត្រ

**(តមកពីលេខមុន)**

បើភិក្ខុទទួលដំណេកក្នុងសេនាសនៈក្នុងព្រៃ លុះភ្ញាក់ឡើងក៏នឹងឮសំឡេង សីហៈ រមាស ខ្លា ជាដើម ត្រឡប់បានបីតិព្រោះនៅក្នុងព្រៃ ហើយក៏ពិចារណានូវសំឡេងនោះថា "អនិច្ចំ ទុក្ខំ អនត្តា" ភិក្ខុនោះនឹងបានលុះអរហត្តផលខ្លះក៏មាន ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលការចូលឈានក្នុងសេនាសនៈ ដែលនៅជិតភូមិជិតស្រុក ហើយទ្រង់សរសើរការទទួលដំណេកក្នុងសេនាសនៈក្នុងព្រៃវិញ ដោយអាស្រ័យអំណាចប្រយោជន៍នោះឯង ។

៧– ភិក្ខុត្រូវតាំងសតិចំពោះខ្លួន មានសេចក្ដីថា: នេវាសិកភិក្ខុអ្នកនៅវត្តខ្លះ មិនមានសទ្ធាជ្រះថ្លា មិនប្រាថ្នានឹងឲ្យមានសព្រហ្មចារីភិក្ខុផងគ្នា មកកាន់អាវាសរបស់ខ្លួន សូម្បីសព្រហ្មចារីដែលមកដល់ហើយ ក៏មិនអើពើមិនធ្វើបដិសណ្ឋារទទួល ម្ល៉ោះហើយទោសនោះនឹងល្បីឮខ្ចរខ្ចាយឡើងថា: នេវាសិកភិក្ខុវត្តឯណោះ មិនមានសទ្ធាជ្រះថ្លាចំពោះសព្រហ្មចារីភិក្ខុអ្នកដំណើរទេ លុះទោសនោះល្បីឮសុសសាយទៅហើយ សូម្បីសព្រហ្មចារីដែលមកដល់មាត់ទ្វារវត្ត ក៏មិនអាចនឹងចូលទៅកាន់វត្តនោះដែរ ដែលបានជាមកមុនជ្រួលដំណើរហើយ ក៏នាំគ្នាដើរចេញអស់ទៅវិញ វត្តនោះនឹងទៅជាវត្តព្រៃផ្សេតឥតមានអ្នកគង់គេតទៅ; ឯនេវាសិកភិក្ខុពួក

នេះ ក៏ខានបានជួបប្រទះនឹងសព្រហ្មចារីអ្នកមានសីល ខានបានស្ដាប់មធុរកថាដ៏ពីរោះអស់ទៅ ការរៀនធម៌ក្ដី ស្វាធ្យាយធម៌ក្ដី ដែលជាប្រ-យោជន៍របស់ខ្លួនក៏លែងបានពីត្រឹមនោះ ៗ ចំណែកខាងឯនេវាសិកភិក្ខុអ្នកមានសទ្ធាជ្រះថ្លា ចូលចិត្តធ្វើបដិសណ្ឋារៈចំពោះសព្រហ្មចារីផងគ្នា រមែងមានកិត្តិស័ព្ទល្បីឮខ្ចរខ្ចាយថា ជាអ្នកមានអធ្យាស្រ័យល្អ ពួកសព្រហ្មចារីភិក្ខុលុះបានឮដូច្នោះក៏និមន្តចុះឡើងហូរហែឥតអាក់, នេវា-សិកភិក្ខុសោតក៏បានសិក្សាធម្មវិន័យ បានតាំងនៅក្នុងឱវាទរបស់សព្រហ្ម-ចារីអ្នកដំណើរជារឿយ ៗ មិនយូរប៉ុន្មាន នេវាសិកភិក្ខុខ្លះក៏បានលុះអរហត្តព្រមទាំងបដិសម្ភិទា ៗ

សេចក្ដីក្នុងអបរិហានីយធម៌ទាំង ៧ ប្រការតាំងអំពីទី ១ ដល់ទី ៧ ដែលបានពោលមកហើយខាងលើនេះ សុទ្ធសឹងជាលទ្ធិពុទ្ធសាសនាក៏ពិតមែន តែគង់នៅមានរស្មីផ្សាយចេញទៅគ្រប់លទ្ធិលោកប៉ុនខ្លះដោយអន្លើៗ ដូចក្នុងខទី ១ ទី ២ នឹងទី ៤ ត្រង់សេចក្ដីថា ត្រូវប្រជុំគ្នារឿយៗ, ត្រូវព្រមព្រៀងគ្នា នឹងត្រូវគោរពអ្នកធំជាដើមនោះជាសេចក្ដីបង្អួលឲ្យឃើញថា ប្រទេសណាក្ដី និគមជនបទណាក្ដី បើមានធម៌ ៣ ប្រការនេះជាកម្លាំងហើយនឹងមានការចំរើនឥតអាក់ មិនងាយនឹងមានឧបស័គ្គអ្វីមួយអាចមករំលាយឲ្យសាបសូន្យបានឡើយ; លុះតែបើខាតធម៌ ៣ ប្រការ

នេះគឺមិនមានការប្រជុំគ្នា មិនព្រមព្រៀងគ្នា និងមិនគោរពអ្នកធំជាដើម ហើយ ប្រទេសនោះ និគមជនបទនោះនឹងសាបសូន្យបាត់ដំឡែងខ្ពង់ខ្ពស់ នឹងធ្លាក់ទៅកាន់ទីថោកទាបពុំខានឡើយ ។

ព្រះញាណកោសល ញាណ - ឈឺន

---

ហេតុបច្ច័យនាំឲ្យកក្រើកផែនដី ៨ យ៉ាង

១ – មហាវាត (ខ្យល់ធំ) បក់ខ្ទាំងធ្វើឲ្យទឹកកក្រើក, ជាហេតុនាំឲ្យកក្រើកដល់ផែនដី ព្រោះផែនដីតាំងនៅលើទឹក ៗ នៅលើខ្យល់ ៗ នៅលើអាកាស ។

២ – សមណៈ- ព្រាហ្មណ៍មានឫទ្ធិឫទេព្តាមានឫទ្ធានុភាពធំ ចំរើនបឋវីសញ្ញាឲ្យមានកំឡាំងខ្សោយ, អាបោសញ្ញាឲ្យមានកំឡាំងលើសលុប ។

៣ – ព្រះពោធិសត្វច្យុតចាកស្ថានតុសិតយាងចុះកាន់ព្រះមាតុឧទរ ។

៤ – ព្រះពោធិសត្វទ្រង់ប្រសូត្រចាកព្រះមាតុឧទរ ។

៥ – ព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ។

៦ – ព្រះសម្ពុទ្ធទ្រង់សំដែងអនុត្តរធម្មចក្រ ។

៧ – ព្រះសម្ពុទ្ធទ្រង់ដាក់ព្រះជន្មាយុសង្ខារ ។

៨ – ព្រះសម្ពុទ្ធទ្រង់ចូលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

(មហាបរិនិព្វានសូត្រ ទីឃ. មហាវគ្គ)

អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបវរកជាតិ
អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិឧកញ៉ាវង្សាសារពេជ្រ នង

ថ្ងៃ-ខែ-ឆ្នាំ កំណើត, ស្រុកកំណើតនិងនាមមាតាបិតានៃឧកញ៉ាវង្សាសារពេជ្រ នង យើងមិនអាចដឹងបាន តាំងពីកាលដែលលោកនៅពីកុមារបានសិក្សាអក្សរសាស្ត្រនិងបួសនៅវត្តណា ក៏មិនប្រាកដដែរ ព្រោះស្រាវជ្រាវរកពុំឃើញ ។ យើងដឹងបានតែត្រង់វេលាដែលបួស ហើយបានរៀនភាសាបាលីព្រះត្រៃបិដក ចេះដឹងជ្រៅជ្រះ ហើយបានចូលប្រឡងបាលីនៅក្រុងបាងកកជាប់បានទីជាមហាផង, មានកិត្តិសព្ទល្បីល្បាញថាជាអ្នកប្រាជ្ញយ៉ាងជំនាញ ១ រូបក្នុងសម័យនោះ ។

ក្រោយនោះ លោកបានជាចៅអធិការវត្តចតុទិស នៅក្រុងឧត្តុង្គ និងបានទទួលសមណសក្តិជាទី មហាព្រហ្មមុនី បានជាគ្រូព្រះរាជបុត្រព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតីទាំង ៤ ព្រះអង្គគឺៈ ព្រះអង្គចន្ទ, ព្រះអង្គស្ងួន, ព្រះអង្គអិមនិងព្រះអង្គដួង ហើយជាឧបជ្ឈាយ៍បំបួសព្រះអង្គដួងជាសាមណេរផង ។

កាលឆ្នាំវក ចត្វាស័ក ពុទ្ធសករាជ ២៣៥៥ ព្រះអង្គអិមទីជា សម្តេចព្រះស្រីជ័យជេដ្ឋាមហាឧបរាជ នឹងព្រះអង្គដួង ស្តេចទៅក្រុងបាងកក, មហាព្រហ្មមុនី នង ក៏បានតាមហែស្តេចទៅផង ។

ចំណោរយូរមក ព្រះអង្គដួងស្តេចត្រឡប់មកព្រះនគរវិញ គង់នៅស្រុកមង្គលបុរី ខែត្របាត់ដំបង ព្រះមហាព្រហ្មមុនីនង ក៏ត្រឡប់មកវិញដែរ នៅជាមួយព្រះអង្គដួង ហើយចាកសិក្ខាបទមានភរិយានៅទីនោះ ។ ភរិយាដំបូងឈ្មោះនាងមាស ។

ក្រោយមក ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមា កាលមុនសោយរាជ្យ បានព្រះរាជទានអ្នកម្នាង ១ នាក់ឈ្មោះតួច ឲ្យជាភរិយាទៀត មានបុត្រ-ធីតា៩នាក់ ដែលកើតអំពីភរិយាទាំងពីរនេះ គឺ: ខាងនាងមាស ៦ នាក់ ( ប្រុស ២ ស្រី ៤ ) នាងតួច ៣ នាក់ ( ប្រុស ២ ស្រី ១ ) ។ ខាងនាងតួចស្លាប់កូនប្រុស ១ ។

កូនប្រុស ៗ សុទ្ធតែបានធ្វើជាមន្ត្រីធំ ៗ ទាំងអស់ ។ ឯកូនស្រី ៗ ក៏បានជាភរិយានៃនាម៉ឺនមុខមន្ត្រីក្នុងជំនាន់នោះទាំងអស់ដែរ ។ ដំណនៃកូនចៅទុកញ៉ាវង្សាសារពេជ្ញ នង នេះ យើងបានស្រាវជ្រាវរកឃើញហូរហែដែរ, តែមិនបាននាំយកមកតពណ៌នាក្នុងទីនេះទេ ។

ក្រោយនោះព្រះអង្គដួងបានប្រាប្តាភិសេក ប្រាកដព្រះនាមាភិធេយ្យជាព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី សោយរាជសម្បត្តិនៅ

ក្រុងឧត្តុង្គមានជ័យ ហើយទ្រង់ព្រះមេត្តាប្រោសយកអ្នកបណ្ឌិតមហា-ព្រហ្មមុនី នង មកតាំងជាអាចារ្យហ្លួង ងារជាឧកញ៉ាវង្សាក្សត្រ ជំណែងចាងហ្លួងក្រមរាជបណ្ឌិត នឹងទ្រង់ព្រះរាជទានស្រុកកោះសុទិនឲ្យជាស្រុកសួយទៀងឧកញ៉ាវង្សាក្សត្រដរាបលុះអស់អាយុ ។

ក្រោយមកលោកបានឡើងជាឧកញ៉ាវង្សាសារពេជ្ញ ។

ឧកញ៉ាវង្សាសារពេជ្ញនង ជាប្អូនបង្កើតរបស់មាតានៃព្រះបរមជាតិស្ត្រីគឺសម្ដេចព្រះវររាជជននីបរមបពិត្រ ដ៏ជាព្រះជននីនាថនៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម ។

លោកឧកញ៉ាវង្សាសារពេជ្ញ នង ជាអ្នកមានប្រាជ្ញាដ៏មុះមុត មានព្យាយាមជាប់ជានិច្ច បានតែងរៀបរៀង សុភាសិតជំបូន្មានទំនងសាស្ត្រផ្សេងៗជាច្រើន, តែដែលយើងបានរកឃើញក្នុងវេលានេះគឺ:

១ - លោកន័យពាក្យកាព្យជារឿងជាតក (តែងកាលនៅក្នុងងារជាឧកញ៉ាវង្សាក្សត្រ) ។

២ - ច្បាប់សុភាសិត ពាក្យកាព្យ ។

៣ - ច្បាប់ស្រី (មិនមែនច្បាប់ស្រីម័យបណ្ឌិតទេ) ។

៤ - ព្រះរាជពង្សាវតារក្រុងកម្ពុជា ។

ម្យ៉ាងទៀត យើងបានប្រទះឃើញឈ្មោះ នង គោរម្យងារជា

ឧកញ៉ាព្រះឃ្លាំង ក្នុងសាស្ត្រាគោតកុលកុមារវង្ស ១ ត្រង់សេចក្តីប្រារព្ធខាងដើម ជាអ្នកតែងសាស្ត្រានោះថា "...កាយោមយា នាមនងជាតិជាឧកញ៉ាព្រះឃ្លាំង គន់គិតកាព្យកិច្ច ពាក្យពេចន៍ទុកតាំង ជាកេរ្តិណាំងតំណសាសនា ..." ដូច្នេះ ៗ យើងសន្និដ្ឋានថាឧកញ៉ាព្រះឃ្លាំងនង នោះគឺជាឧកញ៉ាវង្សាសារពេជ្ញនងនេះឯងហើយ ព្រោះសង្កេតធៀបមើលពាក្យពេចន៍នឹងសំនួនវោហារក្នុងរឿងច្បាប់សុភាសិត នឹងក្នុងរឿងគោត-កុលកុមារនោះដោយសព្វគ្រប់ទៅ ឃើញមានលំនាំបែបបទស្រដៀង ៗ គ្នាគួរឲ្យយល់បានថាជាស្នាដៃអ្នកនិពន្ធតែមួយរូប គឺក្នុងច្បាប់សុភាសិតរបស់លោកឧកញ៉ាវង្សាសារពេជ្ញនង ត្រង់សេចក្តីប្រារព្ធខាងដើមដែរឃើញដាក់សេចក្តីថា "...កាយោមយា នងនាមនា មនោរថំ បីតិ-ឋយោ សីលោរក្ខំ សុភាសិតំ កាព្យករេ... រីអគ្គអញ្ញខ្ញុំ នាមនងសោតសម ចិត្តចេតនា សូមមានមនោ បយោសន្ធា ព្យាយាមឧស្សាហ៍ត្រេកត្រង់កុសល ..." ៗ ប្រហែលជាលោកបានទទួល បណ្តាងារទាំងពីរនេះ ងារណាមួយមុនឬក្រោយបន្ទាប់គ្នា ៗ ប៉ុន្តែការសន្និដ្ឋាននេះក្រែងមិនទាន់ប្រាកដ សូមផ្ញើសេចក្តីស្រាវជ្រាវលើអស់លោកអ្នកប្រវត្តិសាស្ត្រទាំងឡាយតទៅទៀត ៗ

ក្នុងទីបំផុត, យើងមានសេចក្តីស្តាយណាស់ ត្រង់ពុំបានដឹងប្រវត្តិនឹងស្នាដៃរបស់លោកអ្នកប្រាជ្ញរូបនេះដោយល្អិតល្អន់សព្វគ្រប់ ៗ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម

# ប្រវត្តិអក្សរ

កាលមានមនុស្សជាតិកើតឡើងហើយ ក៏មានភាសានិយាយកើតឡើងព្រមជាមួយគ្នា, តែក្នុងជាន់ដើមឯណោះ ពុំទាន់មានអក្សរ សម្រាប់ប្រើកត់ត្រានៅឡើយទេ, លុះចំណេរមកជាច្រើនហ៊ឺនឆ្នាំ ពួកមនុស្សកាន់តែមានសេចក្តីចេះដឹងចំរើនឡើងហើយ ក៏មានប្រាជ្ញាជាយ៉ាងក្រៃពេក ចង់ឲ្យរឿងរ៉ាវសំខាន់ ៗ ក្នុងភាសានោះ មានប្រវត្តិសាស្ត្ររបស់ជាតិជាដើម ស្ថិតនៅអស់កាលជាអង្វែងទៅ ដើម្បីឲ្យអនុជនខាងក្រោយបានដឹងផង ៗ កាលកើតមានគំនិតដូច្នេះជាមូលហេតុហើយ អំពីនោះមកក៏មានអ្នកប្រាជ្ញបានផ្តើមគំនិតគិតធ្វើតួអក្សរសម្រាប់កត់ត្រាឡើង តែគង់រិះរកវិធីធ្វើជាច្រើនបែបច្រើនយ៉ាង អស់វេលាជាយូរឆ្នាំ ទើបសម្រេចកើតជារូបអក្សរឡើង ។

ជនជាតិណា ជាអ្នកផ្តើមគិតបង្កើតតួអក្សរឡើងជាដំបូង?

តាមដែលអ្នកប្រាជ្ញបុរាណគតិ នឹងប្រាជ្ញប្រវត្តិសាស្ត្របានស្រាវជ្រាវមកហើយប្រាកដថា ជនជាតិហ្វេនីស៊ីយាងនៅប្រទេសហ្វេនីស៊ី ដែលមានភូមិភាគតាំងនៅតាមឆ្នេរសមុទ្រ មេឌីតេរ៉ាណេ ប៉ែកខាងកើត ជាអ្នកបានផ្តើមសាងតួអក្សរសម្រេចឡើងជាដំបូង គឺធ្វើជាតួអក្សរមែន ៗ, មិនមែនយករូបវត្ថុផ្សេង ៗ មកសន្មតប្រើជាសំគាល់ ដូចយ៉ាងដែលពួកអឺហ្ស៊ីប នឹងពួកចិន ធ្លាប់ប្រើមកហើយនោះទេ ។ អក្សរហ្វេនីស៊ីយាងនោះ បានចាប់កំណើតឡើងក្នុងលោកជាដំបូង ហើយបានជាដើមត្រកូលរបស់អក្សរនៃជាតិផ្សេង ៗ ក្នុងលោកតមក គឺអក្សរក្រិក, អក្សរឡាតាំង,

# អក្ខរសម្ភព



អក្សរហ្វេនិសីយាន
អក្សរព្រាហ្មី
អក្សរអ៊ឺរ៉ុប
អក្សរផល្លវៈក្រោម
(អក្សរផល្លវៈលើ)
អក្សរខ្មែរបុរាណ
អក្សរមនបុរាណ
អក្សរមូលខ្មែរ
អក្សរជ្រៀងខ្មែរ
អក្សរថៃដើម
អក្សរភូមា
អក្សរថៃសុខោទ័យ
អក្សរអាហោម
អក្សរខ្មែរបែបផ្សេងៗ
អក្សរថៃសៀម
អក្សរលាវលានឆាង
អក្សរលឺនឹងលាវលាននាថៃ
អក្សរឆាន

អក្សរអើរុប, និងអក្សរព្រាហ្មី របស់ព្រាហ្មណ៍នៅជម្ពូទ្វីប (ឥណ្ឌា) ដោយជាតិទាំងនេះបានបំឡងផ្លូវយកទៅប្រើតៗទៅ ។ អក្សរព្រាហ្មីនោះ គេបានប្រទះឃើញចារឹករបស់ព្រះបាទអសោកមហារាជនៃប្រទេសមគធៈ ក្នុងចំណោមដែនឥណ្ឌា ដែលទ្រង់ឲ្យចារឹកទុកក្នុងរវាងពុទ្ធសករាជ៣០០ជាដំបូង ។ អក្សរព្រាហ្មីដែលពោលនេះ គឺពួកព្រាហ្មណ៍ប្រាជ្ញនៅឥណ្ឌាបានផ្ដើមស្ថាបនាឡើង ដោយប្រឌិតយកតាមអក្សរហ្វេនីស៊ីយៈងនោះឯង ។

កាលអក្សរបែបនោះ ត្រូវផ្សាយទៅក្នុងនានាប្រទេសដែលនៅក្នុងទីឆ្ងាយៗពីគ្នា, កន្លងយូរៗមក វិធីសរសេរក៏សន្សឹមៗ ល្អៀងចេញពីបែបដើមទៅខ្លះ, ដល់យូរៗណាស់មកទៀត ក៏រឹតតែប្រែប្រួលបែកចេញទៅផ្សេងៗទៀត ទាល់តែប្រាកដទៅជាបែបផ្សេងគ្នា ។ តាមដែលសង្កេតឃើញមកហើយ អក្សរព្រាហ្មីដែលផ្សាយទៅក្នុងដែនឥណ្ឌា ភាគខាងជើង មានរូបលក្ខណៈជាជ្រុងៗ ទំនងប្រហែលអក្សរខមរបស់យើងក្នុងបច្ចុប្បន្ន អក្សរបែបនេះ គេហៅថា អក្សរនាគរី ឬទេវនាគរី ។ អក្សរព្រាហ្មីដែលផ្សាយទៅក្នុងដែនឥណ្ឌាភាគខាងត្បូងមានរូបលក្ខណៈទ្រង់មូលៗ ប្រហែលនឹងរូបអក្សរមូលរបស់យើង, អក្សរបែបនេះ គេហៅថា គន្ថៈ (គ្រន្ថៈ) ។

អក្សរខ្មែរ នឹងអក្សរមន ជាអំបូរអក្សរគន្ថៈនេះ ។

ខដែលជាដូច្នេះ ដោយប្រាកដតាមប្រវត្តិសាស្ត្រថា ជាតិទាំងពីរនេះ ដើមឡើយនៅក្នុងដែនឥណ្ឌាភាគខាងត្បូង (ទក្ខិណាបថ)[១] ឯណោះ បានធ្លាប់ប្រើអក្សរបែបនោះ ជាអក្សរសម្រាប់ជាតិរបស់ខ្លួនមកហើយ កាលផ្សាយចុះមកតាំងឥស្សរភាពនៅក្នុងប្រទេសបច្ចុប្បន្ននេះក៏បាននាំយកអក្សរ នឹងលទ្ធិទំនៀម–សាសនាសម្រាប់ជាតិរបស់ខ្លួនមកប្រើ នឹងប្រព្រឹត្តប្រតិបត្តិ ដូចកាលនៅប្រទេសដើម ៗ តែអក្សរនោះ ពុំបានគង់ទ្រង់រូបលក្ខណៈនឹងចំនួននៅដូចរបៀបដើមទាំងស្រុងទេ រមែងមានការណ៍ប្រែប្រួល ដោយគេត្រូវការសម្រួលទៅតាមកាល-ទេសនិយម បន្តិចម្តងៗ រៀងរាបមក, តាមដែលសង្កេតឃើញអក្សរខ្មែរ សម័យនគរភ្នំដែលជាសម័យដំបូងរបស់ខ្មែរនៅស្រុកអាយនេះ មានរូបលក្ខណៈទ្រង់មូលៗ មានសរសៃល្វន (ចូរមើលអក្សរចារិកក្នុងសម័យនោះ) លុះចំណេរមកដល់សម័យនគរធំ (ក្រុងស្រីយសោធរបុរៈ) អក្សរយើងបានប្រែរូបលក្ខណៈទៅជាជ្រុងៗ គឺរូបស្ទើរជា ៤ ជ្រុង (ចូរមើលអក្សរចារិកក្នុងសម័យនោះ មានអក្សរចារិករបស់ព្រះបាទយសោ-វរ្ម័នទី ១ ជាដើម) ។ សុំបញ្ជាក់ជាឧឡារិកថា អក្សរចារិកនៅអង្គជំទឹកក្នុងឃុំកោះ ស្រុកបាភ្នំ ដែលគេចារិកទុកក្នុងរវាងសតវត្សទី ៧ ដូចគ្នានឹង

---

១ ចូរមើលព្រះរាជពង្សាវតារ សម័យនគរភ្នំ ដែលបោះពុម្ពនៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៤៩ ផងចុះ ។

អក្សរចារិករបស់ក្សត្រិយវង្សចលុក្យៈ ដែលទ្រង់បានឲ្យចារិកទុកនៅប្រាសាទ ពានាមិ, ឰហោល, បដ្ដទកល, ក្នុងទក្ខិណប្រទេស,(១) ក្រោយនោះមកក៏សន្សឹមក្លាយបន្តិចម្តងៗ ទាល់តែល្អៀងមកជាអក្សរដែលយើងប្រើសព្វថ្ងៃនេះ ។

ស្រៈក្នុងជាន់ដើម (សម័យនគរភ្នំ - នគរធំ) ខ្មែរយើងប្រើតែតាមស្រៈក្នុងភាសាសំស្ក្រឹតនឹងភាសាមគធៈ ។ ក្នុងភាសាសំស្ក្រឹតស្រៈមាន ១៤ តួ គឺ អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ហើយនឹងវិសជ្ជនីយ (ះ) ។ ស្រៈក្នុងភាសាមគធៈ (បាលី) មាន ៨ តួ គឺ អ អា អិ អី អុ អូ អេ អោ ។ ខ្មែរយើងប្រើតែស្រៈប៉ុណ្ណោះដរាបមកដល់ផុតសម័យនគរធំ ។ (ចូរមើលសិលាចារិកទាំងឡាយក្នុងសម័យនគរធំ) ។ លុះផុតសម័យនគរធំ មកដល់សតវត្សទី ១៥-១៧ នៃ គ. ស. ទើបឃើញមានបន្ថែមស្រៈថ្មីៗ ឡើងទៀតជាច្រើន គឺស្រៈ អឹ អឺ អួ អឿ អៀ អែ ចូរមើលសៀវភៅ "សិលាចារិកនគរវត្ត"(២) ដែលបោះពុម្ពហើយនៅពុទ្ធសាសនបណ្ឌិត្យ ។ លំដាប់ពីនោះមក ទើបឃើញមានប្រើស្រៈ អុំ អំ អាំ ។ តែ អុំ អំ អាំ នេះ មិនគួរចាត់ជាស្រៈទេ ព្រោះប្រកប

---

១ អក្សរចារិកនៅប្រាសាទពានាមិ មានបែបនៅក្នុងសៀវភៅ Le cambodge របស់លោក Aymonier ។ ក្នុងសៀវភៅនោះ មានទាំងអក្សរចារិកអង្គជំនឹក សរាប់ធៀបគ្នាផង ។ ២ គេចារិកនៅសសរប្រាសាទនគរវត្តត្រង់ថ្នាក់ព្រះពាន់, ក្នុងសម័យលង្វែក ។

ដោយនិគ្គហិត ហើយអានដូចសង្កត់ដោយអក្សរម. ឬបុកណាគេសរសេរ
**ដើំ** អានថា ដើម, **ក្រោំ** អានថា ក្រោម ។ល។

ព្យញ្ជនៈតាមចំនួនដើម ដែលខ្មែរយើងកំពុងនិយមប្រើភាសាសំស្ក្រឹតជាសំខាន់នោះ មាន ៣៥ តួ ច្រើនជាងក្នុងបច្ចុប្បន្ននេះ ២ តួ គឺមានអក្សរ ឝ ឞ ដែលនៅត្រង់រវាងអក្សរ ស និងអក្សរ ហ, ព្យញ្ជនៈ ២ តួនេះ សម្រាប់ប្រើចំពោះតែក្នុងភាសាសំស្ក្រឹត លុះអំណើះតមក ខ្មែរយើងថយសេចក្ដីចេះដឹងភាសាសំស្ក្រឹត ត្រឡប់ឃើញហាក់ដូចជាអក្សរ ២ តួនេះគ្មានប្រយោជន៍ ឬលើសសេចក្ដីត្រូវការប្រើ ទើបបោះបង់ចោល តែទើបនឹងបោះបង់ស្មោះក្នុងរយៈវេលាប្រមាណ ៥០ ៦០ ឆ្នាំមកនេះ ។

វិធីសរសេរអក្សរខ្មែរក្នុងជាន់ដើម ឃើញមានតែ ២ បែបដូចបានពោលមកខាងដើម លុះមកដល់សម័យលង្វែក ទើបឃើញមានសរសេរជាច្រើនបែប គឺក្រៅពីបែបមូល - ខមហើយក៏មានបែបអក្សរជ្រៀង អក្សរឈរ អក្សរខ្សៀក ឬអក្សរកែ ជាដើម ។ អក្សរបែបក្រោយទាំងប៉ុន្មានយ៉ាងនេះ ប្រសិនជាឲ្យបុព្វបុរសសម័យនគរភ្នំ នគរធំអាន ខ្ញុំស្មានថាមិនងាយនឹងអានបានទេ ទំនងដូចពួកយើងក្នុងសម័យនេះ មិនអាចនឹងអានអក្សរបែបបុកណាបានដូច្នោះដែរ ។

តាមប្រវត្តិសាស្ត្រ ទាំងតាមកស្តុតាងដែលមាននៅក្នុងបច្ចុប្បន្ននេះ ជាតិខ្មែរយើងប្រាកដថាជាជាតិ ១ ដែលមានអារ្យធម៌ខ្ពង់ខ្ពស់ថ្លៃថ្នូរជាងជាតិទាំងឡាយដែលនៅក្នុងដែនសុវណ្ណភូមិ ។ ជាតិទាំងឡាយដែលនៅក្រោមឥទ្ធិពលខ្មែរ ឬនៅជិតខាងប្រទេសខ្មែរ សុទ្ធតែបានទទួលស្ទើអារ្យធម៌ទៅអំពីខ្មែរស្ទើរតែទាំងអស់ ដោយហេតុនេះ ជាតិខ្មែរទើបមានអតិរេកនាមជាកិត្តិយស ប្រាកដនៅក្នុងប្រវត្តិសាស្ត្រថាជា "ឥណ្ឌាទី ២ នៅក្នុងដែនសុវណ្ណភូមិ" គឺជាដែនកណ្តាលនៃការផ្ទេរអារ្យធម៌ពីឥណ្ឌាមក ទំនងដូចជាជាតិរ៉ូម ជាដែនកណ្តាលនៃការផ្ទេរអារ្យធម៌ក្រិកមក ។ ពោលដោយចំពោះជាតិថៃ (សៀម) ទាំងជាតិលាវ សុទ្ធសឹងតែបានទទួលអារ្យធម៌ខ្មែរ មានបែបអក្សរសាស្ត្រជាដើម ទៅជាសម្បត្តិរបស់ខ្លួន ។ សេចក្តីពិត ជាតិថៃ កាលនៅក្នុងប្រទេសដើម (យុណាន ឬហ៊ុនណាំ) របស់ខ្លួននោះ ពុំទាន់មានអក្សរសម្រាប់ជាតិខ្លួនប្រើនៅឡើយ, លុះមកដល់សម័យ ១ ជាតិថៃ ត្រូវចិនរុករានខ្លាំង តស៊ូពុំបាន, ជាតិថៃភាគច្រើនបានបោះបង់ចោលប្រទេសរបស់ខ្លួន ប្រទេសថៃក៏រលាយទៅជាប្រទេសចិន ដរាបដល់សព្វថ្ងៃនេះ ។ គ្រានោះមានជាតិថៃជាច្រើនហ្មឺននាក់ បាននាំគ្នាចុះមកអាស្រ័យនៅតាមដាយដែនកម្ពុជរដ្ឋភាគខាងលើ រៀងទៅដល់ប្រទេសមន ។ ជាតិថៃដែលមកនៅក្នុងដែន

កម្ពុជរដ្ឋគ្រានោះ គឺនៅក្នុងឋានៈជាចំណុះខ្មែរ អស់រយៈវេលាជាច្រើន សតវត្សរ៍គឺមិនតិចជាង ៣០០ ឆ្នាំ ។

លុះមកដល់ប្រមាណក្នុងរវាង ព.ស. ១៨០០ ជាពេលដែលក្សត្រិយ៍ខ្មែរថយអានុភាពចុះ ថៃក៏ឆក់យកឱកាសនោះ តាំងឥស្សរភាពឡើងនៅក្នុងជាយដែនប្រទេសកម្ពុជាភាគខាងលើ គឺតាំងរាជធានីនៅស្រុកសុខោទ័យជាដំបូង, ក្សត្រិយ៍អង្គដំបូងទ្រង់ព្រះនាមហៅតាមពាក្យសាមញ្ញថា "ពញាកេង" ។ មកដល់ក្នុងឆ្នាំ ព.ស. ១៨២៦ ឃុនរាមកំហែងជាឱរស បានសោយរាជ្យជាក្សត្រិយ៍ទី ៣ បានផ្ដើមបង្កើតបែបអក្សរថៃឡើងជាបឋម ។ ការដែលថៃគិតសាងបែបអក្សរសម្រាប់ជាតិនោះគឺគិតប្រឌិតយកតាមបែបអក្សរខ្មែរនេះឯង ។ ខ្ញុំពិនិត្យឃើញយ៉ាងជាក់ថាថៃបានប្រឌិតដើមអក្សរខ្មែរទៅជាតួអក្សរថៃ ។ ក្នុងខនេះពួកអ្នកប្រាជ្ញថៃក្នុងបច្ចុប្បន្នមានហ្លួងវិចិត្រវាទការជាដើម បានទទួលស្គាល់នឹងរ៉ាប់រងយ៉ាងនេះហើយ ។ ទាំងជាតិលាវក៏បានផ្ទេរយកបែបអក្សរខ្មែរទៅប្រើដូចជាថៃនោះដែរ ។

ក្នុងសៀវភៅ "ដំណាលអក្សរថៃ" ថា "ពួកស្យាមនឹងលាវលានឆាងធ្លាប់នៅក្នុងអំណាចខ្មែរ ធ្លាប់ប្រើភាសានឹងអក្សរខ្មែរ ក្នុងផ្លូវការមកហើយ, ដោយហេតុនេះ ក្នុងភាសាស្យាមនឹងភាសាលាវលានឆាង ទើបមានភាសាខ្មែរលាយចម្រុះជាច្រើន, ទាំងអក្សរថៃសុខោទ័យ

ទាំងអក្សរលាវលាននាង ក៏កើតចេញពីអក្សរខ្មែរដោយពិត ។ ឯវិធីប្រើអក្សរនោះ មានដូចខ្មែរជាច្រើន, មានខុសគ្នាខ្លះដែរ តែមិនបាច់អធិប្បាយឲ្យល្អិតទុកក្នុងទីនេះទេ, សូមតែបញ្ជាក់ថា អារ្យធម៌ខ្មែរក្នុងជំនាន់នោះបានជាប្រយោជន៍ដល់ជាតិថៃ - លាវ និងជាតិដែលនៅជិតខាងជាយ៉ាងច្រើនដែលអ្នកសិក្សាប្រវត្តិសាស្ត្រខ្មែរមិនគប្បីភ្លេចឡើយ ។

ឧកញ៉ាទេពពិទូរ, ឈម - ក្រសេម

---

# ស្នាដៃឧកញ៉ាវង្សាសារពេជ្រនង

(ដកស្រង់ពីច្បាប់សុភាសិត)

លោកថាព្រះ ច័ន្ទវែងរៀងរះ ពេញបុណ្ណមិយំ ពុំល្អប្រពៃ ស្មើថ្ងៃឯកំ មិតិត្តយំ មួយពេចឡើយហោង ។ មួយនីនៃអ្នក ចេះសិល្បសិទ្ធិស័ក្តិ គាថាមន្តផង បើពុំចាំមាត់ ស្មើស្មោកជាមួង ពុំប្រសើរហោងជាចេះឡើយណា ។ វីរអ្នកទាហាន សេនាថ្កើងថ្កាន សាហ័សក្លៀវក្លា បើគ្មានថ្វីដៃ ឥតជ័យចេស្តា ពុំរាប់ហៅថា ទាហានឡើយនៃ ។ មួយសោតគជសារ ធាត់ធំឧទារ ខ្លាះខ្លាំងនិរភ័យ បើបានចូលសឹក ពន្លឹកជាញជ័យរែងមានតេជដៃ ទើបប្រសើរហោង ។ មួយសោតលោកថា ស្រីមានរូបា សោឡសឆ្នាំផង ពុំហៅល្អល្អះ ត្រុះបះហ្មត់ហ្មង់ លុះមានកូនម្តងសុះសោកគេ ។

តាំងពីកាលនោះមក, គាត់មិនសូវរវល់ធ្វើសិទ្ធស្នាលជាមួយជនណាមួយទេ គិតតែពីរក្សាទ្រព្យសម្បត្តិនោះ លាក់ទុកក្រោមក្បៀកជាប់មិនដែលហ៊ានឲ្យឃ្លាតចេញពីខ្លួនឡើយ, ព្រោះថា:–

១៦៣– ការរកទ្រព្យសម្បត្តិជាទុក្ខ ការរក្សាទ្រព្យសម្បត្តិដែលបានមកហើយជាទុក្ខ ការបានទ្រព្យសម្បត្តិជាទុក្ខ ការវិនាសទ្រព្យសម្បត្តិជាទុក្ខ; ឱហ្ន៎! ទ្រព្យសម្បត្តិនេះ ពេញបរិបូណ៌ដោយសេចក្តីទុក្ខលំបាកណាស់តើ! ។

កាលនោះ មានចោរចិលម្នាក់ឈ្មោះអាសាឍភូតិ ឃើញបរិព្វាជកនោះនៅក្នុងព្រៃស្ងាត់មានប្រាក់កាសច្រើន ក៏គិតរកឧបាយលួចថា: ធ្វើដូចម្តេចអេះ នឹងចូលទៅលួចយកទ្រព្យសម្បត្តិនោះបាន? អាស្រមនេះ មានកំពែងព័ទ្ធជុំវិញ នឹងចោះចូលទៅក៏មិនបាន ព្រោះគេបូកបាយអជាប់មាំមួនណាស់ បើនឹងចូលទៅតាមទ្វារក៏មិនបានដែរ ព្រោះទ្វារនោះខ្ពស់ពេក បើដូច្នោះ គួរអាត្មាអញក្លែងធ្វើជាអ្នកបួសចូលទៅរាយអែបឲ្យស្និទ្ធ ហើយនិយាយពាក់ចេកពាក់ស្ករដោយឧបាយឆបោកយកខ្លួនទុកដូចជាកូនសិស្សវិញ ដើម្បីនឹងឲ្យគាត់ទុកចិត្តជាមុនសិន, ព្រោះថា:–

១៦៨ – អ្នកមិនមានថ្វីមាត់ មិនអាចនឹងនិយាយពាក្យពិរោះបានទេ អ្នកនិយាយត្រង់ៗ ធ្វើជាអ្នកឆបោកមិនបានទេ អ្នកមិនចង់ធំ ធ្វើអធិការមិនបានទេ អ្នកមិនបរិភោគកាម មិនស្រឡាញ់គ្រឿងតែងកាយទេ ។

លុះចោរវិលគិតរកឧបាយបានស្រេចហើយ ទើបចូលទៅកាន់សំណាក់បរិព្វាជកទេវសម៌: ចូលទៅដល់ហើយ លុតជង្គង់ចុះក្រាបថ្វាយបង្គំហើយស្ងូត្រស្តុតីថា: "ឱម! សូមនមស្សការព្រះឥស្សរជាកំពូលលោក" ទើបនិយាយរៀបរាប់ដោយគោរពថា: "គតកន ! សំសារនេះ ឥតខ្លឹមសារទេ យៅវនភាពទុកដូចសន្ទះខ្សែទឹកស្ទឹងដែលហូរខ្លាញ់ចេញពីកំពូលភ្នំ ជីវិតទុកដូចជាភ្លើងចេះស្មៅ សេចក្ដីរីករាយទុកដូចជាម្ទប់នៃពពកក្នុងវេហាស៍ ការជួបជុំមួយអន្លើដោយបុត្រធីតា ដោយភរិយា ដោយមិត្រនឹងបរិវារ ទុកដូចជាយល់សប្ដិ ខ្ញុំបានយល់ដូច្នេះច្បាស់លាស់ក្នុងចិត្តណាស់លោកម្ចាស់ ! ធ្វើដូចម្ដេចហ្ន៎ បុគ្គលនឹងគប្បីឆ្លងនូវសមុទ្រគោលគឺសង្សារវដ្ដនេះបាន?" ។ ទេវសម៌: បានស្ដាប់ពាក្យអាសាឍភូតនេះចប់ហើយ ក៏ឆ្លើយតបដោយសាទរថា: "កូនអើយ ! ឯងមានភ័ព្វសំណាងណាស់ ! តំណូចឯងប៉ុណ្ណោះឯងចេះដឹង ឯងចេះស្គាល់សេចក្ដីទុក្ខក្នុងលោក, ព្រោះថា: –

១៦៩ – នរជនណា មានសេចក្ដីក្សាន្តតាំងពីបឋមវ័យ នរជននោះឈ្មោះថាជាអ្នកក្សាន្ត នេះជាមតិខ្ញុំ ព្រោះថា កាលបើធាតុរលត់រលាយអស់ហើយ សេចក្ដីស្ងប់នៃជនណានឹងមិនកើតមានទៀត? ។

១៦៦ – លោកសប្បុរស តែងចាស់ចិត្តមុន ទើបចាស់កាយក្រោយ ឯអសប្បុរសវិញ ក្នុងកាលណាដោយ តែងចាស់កាយមុន តែចិត្តមិនចាស់ទេ ។

អើ! ឯងចូលមកនេះ ដើម្បីសាកសួររកឧបាយនឹងឆ្លងសាគរគឺសង្សារវដ្តចំពោះយើង ដូច្នោះឯងចូរប្រុងស្តាប់ចុះ :–

១៦៧ – ជនត្រកូលសូទ្រៈក្តី ឬជនត្រកូលចណ្ឌាលក្តី ពុំនោះជនណាមួយដទៃក្តី ថាបើបានទ្រទ្រង់ជដា បានបំពេញយញ្ញៈ ដោយសិវមន្ត្រ មានសពាង្គកាយប្រោះព្រំដោយផេះ នឹងបានសួស្តីសិរីមង្គល ។

១៦៨ – នរជនណា បានបូជាផ្កាសូម្បីមួយទងដោយខ្លួនឯងនៅលើសិវលិង្គ ដោយមន្ត្រប្រកបដោយអក្សរ ៦ តួ[១] នរជននោះ នឹងមិនកើតទៀតទេ ។

អាសាឍកុតិ លុះបានស្តាប់ហើយក៏សំដែងអាការហាក់ជាពេញចិត្តណាស់ លូកដៃចូលទៅចាប់ជើងទេវសមិៈ ហើយពោលដោយគោរពថាៈ "ភគវាន! សូមមេត្តាសង្គ្រោះប្រោសសត្វឲ្យទាន" ។ ទេវសមិៈឆ្លើយតបថា "កូនអើយ! អាត្មាព្រមសង្គ្រោះបាន, ប៉ុន្តែ វេលាយប់ឯងចូលមកនៅក្នុងអាស្រមនេះមិនបានទេ ព្រោះថាអ្នកបំពេញព្រត

---

១ ឱម នមៈ សិវាយ ។

នៅប្រុះប្រួមគ្នាមិនបាន ឯងនៅជាមួយអាត្មាក៏មិនបាន អាត្មានៅជាមួយឯង ក៏មិនបានដែរ ព្រោះថាៈ –

១៦៩ – ព្រះនរបតី វិនាសព្រោះទុកទំមិនល្អ អ្នកបំពេញព្រត វិនាសព្រោះការនៅប្រឡុកប្រឡល់ កូន វិនាសព្រោះការស្រឡាញ់ (ការថ្នម) ព្រាហ្មណ៍ វិនាសព្រោះការមិនស្វាធ្យាយ ត្រកូល វិនាសព្រោះកូនអាក្រក់ សេចក្ដីស្នេហា វិនាសព្រោះការអាស្រ័យនៅឆ្ងាយគ្នា មេត្រីភាព វិនាសព្រោះការមិនទោរទន់ទៅមករកគ្នា សេចក្ដីសម្រេច វិនាសព្រោះការប្រតិបត្តិមិនល្អ ចរិយា វិនាសព្រោះការសេពគប់ជនទុច្ចរិត ស្រី វិនាសព្រោះការព្រោយបុកផងនឹងការព្រងើយកន្តើយផង កសិកម្ម វិនាសព្រោះការបោះបង់ចោល ទ្រព្យវិនាសព្រោះការប្រមាទ ។

ដូច្នេះ បើឯងចង់បំពេញព្រត ហើយហ៊ានដេកនៅមាត់ទ្វារអាស្រម កន្ទេលខ្លួនតូចប្រក់ស្មៅនេះទើបបាន" ។ អាសាឍកុមារ ឆ្លើយតបដោយពេញចិត្តថាៈ "កគណ ! ខ្ញុំករុណាធ្វើតាមពាក្យបង្គាប់គ្រប់ប្រការ ព្រោះខ្ញុំករុណាប្រតិបត្តិបំពោះទៅកាន់បរលោក" ។ កាលអាសាឍកុមារព្រមសន្យាថានឹងសុខចិត្តដេកកន្ទេលខ្លួនប្រក់ស្មៅ ក្រៅអាស្រមដើម្បីបំពេញព្រតដូច្នេះហើយ ទេវសមិៈ ទើបព្រមអនុញ្ញាតឲ្យធ្វើជាកូនសិស្សព្រមបំបួសទៅតាមវិន័យដែលមានក្នុងកន្ទងគម្ពីរវេទ ។ ឯអាសាឍកុមារ

ខំប្រតិបត្តិគ្រូមិនហ៊ានធ្វើឲ្យគ្រូឃ្នើសឃ្នងព្រះទ័យទេ ផ្គត់ផ្គង់មិនឲ្យមោះហ្មងតាំងពីការច្របាច់នួតដៃជើងប្រគេនជាដើមទៅ ទាល់តែលោកគ្រូពេញចិត្ត តែលោកគ្រូនៅតែមិនហ៊ានប្រហែសកញ្ចប់ប្រាក់សោះ លោកតែងតែយកទៅលាក់ទុកក្រោមក្លៀកជាប់ជានិច្ច មិនដែលហ៊ានបោះបង់ម្ដងណាឡើយ ។ ហេតុការណ៍យ៉ាងនេះប្រព្រឹត្តទៅអស់កាលយូរណាស់ ទាល់តែអាសាឍកុតិអត់ទ្រាំទៅតទៅមិនបាន ក៏គិតរកឧបាយថ្មីទៀតថា: “ អ៊ា ! លោកគ្រូនេះជើងតឹងតែងមែន ! ” នៅមិនទាន់ទុកចិត្តអាត្មាអញសោះ បើដូច្នោះគិតធ្វើដូចម្ដេចទៀតអេះ ? ឥឡូវនេះអាត្មាអញនឹងសម្លាប់គាត់ទាំងថ្ងៃដោយគ្រឿងអាវុធឬ បំពុលសម្លាប់ ពុំនោះសម្លាប់ចោលដោយឧបាយដូចជាសត្វខាំសម្លាប់ ? „ ។ ក្នុងពេលដែលអាចោរខិលកំពុងតែគិតដូច្នេះ កូនប្រុសរបស់សិស្សនៃទេវសម៌ ម្នាក់ចូលមកដល់ពីភូមិ សូមនិមន្តទេវសម៌:ថា “ កគវ៉ន សូមនិមន្តទៅកាន់ផ្ទះខ្ញុំករុណា ដើម្បីធ្វើបវិត្រាពេហណ:(១) „ ។ ទេវសម៌:ព្រមទទួលនិមន្តដោយរីករាយហើយក៏ធ្វើដំណើរចេញទៅជាមួយអាសាឍកុតិ ទៅដល់

---

១ — ពិធីកាលជាបវិត្ររោហណៈ ជាពិធីយញ្ញ បំពោះព្រះទុគ៌ា ជាសក្ដិព្រះឥស្វរ គេតែងធ្វើនៅថ្ងៃ ៨ កើតខែស្រាពណ៍ ឬខែអាសាឍ ។ ពិធីកាលគេធ្វើចំពោះរូបព្រះក្រិស្ណៈ នៅថ្ងៃ ១២ កើតខែស្រាពណ៍ ។ មានសេចក្ដីខ្លះថា គេតែងធ្វើពិធីនេះច្រើនយ៉ាង ចំពោះទេវតាផ្សេងៗ ក្នុងផ្លូវផ្សេងៗ គ្នា ។

ពាក់កណ្ដាលផ្លូវ ប្រទះស្ទឹងមួយ គាត់ត្រូវការមុជទឹកទើបដកថង់ដាក់ប្រាក់ចេញពីក្លៀក ហើយខ្ចប់ទឹងកំណាត់សំពត់លាក់ទុកដោយប្រពៃ ចុះទៅមុជទឹករួចហើយធ្វើការវៈដល់ទេវតា ទីបំផុតនិយាយប្រាប់អាសាឍកូតិថា: នែអាសាឍកូតិ ដរាបណា អញទៅបន្ទោបង់លាមកហើយត្រឡប់មកវិញ ដរាបនោះ ឯងត្រូវប្រយ័ត្នប្រយែងរក្សាកំណាត់សំពត់យោកេស្វរ.[1] នេះកុំប្រហែសធ្វេសឲ្យសោះ និយាយផ្ដាំរួចហើយគាត់ដើរចេញទៅ ៗ កាលទេវសមិៈដើរចេញទៅ គ្រាន់តែកំបាំងភ្នែកមើលមិនឃើញអាសាឍកូតក៏ក្រសោបយកថង់ប្រាក់នោះរត់គេចចេញទៅបាត់ភ្លាម ៗ ឯទេវសមិៈ ដោយក្ដីពេញចិត្តចំពោះគុណសម្បត្តិ ព្រមទាំងជឿទុកចិត្តសិស្សវិលអស់ពីពោះពុង គិតតែពីអង្គុយប្រហោងបន្ទោបង់ ភ្នែកអាល័យតែមើលចម្បាំងពពែនៅកណ្ដាលហ្វូងពពែ ៗ ឯពពែទាំងពីរដែលជល់គ្នា កំពុងតែក្រពុលមុខ ថយក្រោយទាំងពីរ ហើយលោតសំរុកទៅជល់គ្នា ទង្គិចក្បាលគ្នាទៅវិញទៅមកឮសូរក្ដាំងៗ ធ្វើយ៉ាងនេះច្រើនដងណាស់ ទាល់តែឈាមហូរចេញសស្រាក់ ពេលនោះ មានចចកមួយហោលត្រឹកៗ មកមិនដឹងជាមកពីណា ចូលទៅក្នុងទីដែលពពែជល់គ្នានោះ ចូលទៅហើយឃើញឈាមពពែ ក៏លិទ្ធដោយសេចក្ដីស្រេកឃ្លាន ៗ

(មានត)

---

(១) តាមព្រះឥសូរ ។

# សេចក្ដីថ្លែងការ

ក្នុងថ្ងៃទី ២៥ ខែកុម្ភៈ ព. ស. ២៤៩៣ (គ. ស. ១៩៥១) សមាគមមិត្តសាលាបាលីបានផ្ដើមធ្វើពិធីបុណ្យ ប្រគេនព្រហ្មទានជាលើកទី ២ ដល់ព្រះសង្ឃជាសិស្សសាលាបាលីជាន់ខ្ពស់ចំនួន ៨៨ រូបដែលទើបនឹងប្រឡងជាប់សញ្ញាបត្រសាលានេះក្នុងឆ្នាំ ១៩៥១ ។

ពិធីបុណ្យនេះបានរៀបចំធ្វើនៅសាលាបាលីជាន់ខ្ពស់ ចាប់តាំងពីល្ងាចថ្ងៃ ២៤ កុម្ភៈមក, មានតាំងការចំរើនព្រះបរិត្តនិងធម្មទេសនាផង, ជាកិច្ចដ៏ឧឡារិកអធិកជាងឆ្នាំមុន ដោយសារសេចក្ដីជ្រះថ្លានិងការឧបត្ថម្ភដ៏លើសលប់នៃអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ ។

ចំណែកព្រហ្មទានដែលអស់លោកអ្នកសប្បុរសបានចូល កាន់អង្គទាំងអស់បានចំនួន ១០៦ ។ ចំនួនសិស្សតែ ៨៨ រូប, ឃើញថាលើសទេយ្យវត្ថុ ១៨ ។ វត្ថុលើសនេះ បានប្រគេនដល់ព្រះថេរៈទាំងឡាយដែលជាចាងហ្វាងនិងជាសាស្ត្រាចារ្យនៃសាលាបាលីជាន់ខ្ពស់ ព្រមទាំងសិស្សដែលប្រឡងធ្លាក់ ៣ រូបទៀតផង ។

ថ្ងៃទី ២៥, ពេលម៉ោង ៤ រសៀល, ជួបជុំព្រះសង្ឃនិងសិស្សព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីនូវអស់លោកអ្នក ពុទ្ធបរិស័ទទាំងឡាយ ។

ម៉ោង ៥, ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់បានស្ដេចយាងទៅដល់យ៉ាសាលាបាលីជាន់ខ្ពស់ ដោយមានរាជបរិពារហែហមព្រះអង្គផង

ព្រមទាំងមានក្រុមយោធាទឹងក្មេងជាតិចាំទទួលធ្វើការកិច្ច ។ ខណៈនោះ, លោកអធិបតីសមាគមបានថ្វែងសុន្ទរកថាទទួលព្រះរាជអំណារព្រះមហាក្សត្រ ទឹងរៀបរាប់អំពីវត្ថុបំណងរបស់សមាគមដែលផ្គងជួយឧបត្ថម្ភពុទ្ធសាសនាទឹងអក្សរសាស្ត្រ ព្រមទាំងសារសព្វអំពីកិត្តិគុណនៃសាលាបាលីជាន់ខ្ពស់ ដោយការលើកសេចក្ដីប្រៀបធៀបជាច្រើន ៗ បន្ទាប់មក, ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់បានថ្វែងសុន្ទរកថាតបយ៉ាងក្បោះក្បាយ ៗ រួចហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រគេនសញ្ញាបត្រទឹងព្រហ្មទានរបស់ព្រះអង្គដល់សិស្សដែលប្រឡងជាប់លេខ ១ ៗ ចំណែកអស់លោកអ្នកកាន់អង្គឯទៀត ៗ ក៏បានលើកព្រហ្មទានប្រគេនបន្ត ៗ គ្នាចំពោះសិស្សទាំងឡាយ ហូរហែតាមលំដាប់លេខរហូតដល់ ៤៨ ៗ រួចកិច្ចប្រគេនហើយ, ព្រះមហាក្សត្រ ទ្រង់ថ្វែងព្រះរាជសុន្ទរកថាយ៉ាងសង្ខេបសរសើរអំពីវិរិយភាពនៃសិស្សទាំងឡាយព្រមទាំងទ្រង់ទទួលអំណរដ៏ពន្លឹកដល់ពួកពុទ្ធបរិស័ទ ដែលបានបំណាយបច្ច័យជាកំឡាំងកងទេយ្យទាននោះ ៗ លុះចប់ព្រះរាជសុន្ទរកថាហើយ ទើបព្រះសង្ឃសូត្រជយន្តោ ទឹងអនុមោទនាដោយមង្គលទាំងពួង ជាកិច្ចបង្ហើយពិធីបុណ្យ ៗ

តទៅនេះគឺសេចក្ដីដកស្រង់សុន្ទរកថា លោកអធិបតីសមាគមនឹងព្រះតេជព្រះគុណព្រះពោធិវង្ស ដោយអន្លើ ៗ ចំពោះត្រង់ដែលមានប្រយោជន៍ច្រើន ព្រមទាំងព្រះរាជសុន្ទរកថាទាំងអស់ៈ

## សុន្ទរកថាលោកអធិបតីសមាគម

" . . . ហេតុនេះគួរទុកសមាគមនេះ ជាកម្លាំងរបស់សាលាបាលី-ជាន់ខ្ពស់ ដែលជាព្រះរាជកិត្តិយសនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះវិរិយភាពស្អាងវិជ្ជាស្ថានដ៏ឧត្តម សម្រាប់ផ្សាយកិត្តិស័ព្ទនៃពុទ្ធសាសនានិងអក្សរសាស្ត្រ, អភិបាលរក្សានូវភាសាបាលីនិងភាសាជាតិព្រមទាំងវប្បធម៌ខ្មែរ ទំនៀមទំលាប់ខ្មែរ ឲ្យគង់ទ្រង់រហូតមកដល់សម័យបច្ចុប្បន្ននេះ ។ សាលាបាលីជាន់ខ្ពស់មិនមែនមានកិត្តិគុណត្រឹមប៉ុណ្ណោះទេ គឺជាសាលាមួយសម្រាប់អប់រំខាងគុរុវិទ្យាផ្នែកសាសនានឹងអក្សរខ្មែរ-បាលី ដើម្បីនឹងផ្ទេរបំណេះនេះទៅជនជាតិខ្មែរគ្រប់ភូមិស្រុកនិគមជនបទក្នុងកម្ពុជរដ្ឋ ។ ព្រះសង្ឃទាំងនេះ ជាគ្រូបាអាចារ្យនៃជនជាតិខ្មែរដោយភាគច្រើន ព្រោះលោកតែងនិមន្តទៅទេសនាទូន្មានប្រ-ដៅធម៌វិន័យគ្រប់ប្រកល្ហកជានិរន្តរកាល ។ ព្រះមហាក្សត្រទុកជាវត្ថុធាតុដ៏ឧត្តម, សាលាបាលីជាន់ខ្ពស់ទុកជាដើមរុក្ខា, ព្រះសង្ឃជាបុប្ផាក្រអូប, ឧបាសកឧបាសិកា ជាឃ្មុំឬកន្ធង់ដែលតែងជញ្ជក់នូវលំអងបុប្ផាទាំងនោះមកធ្វើសំបុកគឺបំណេះគ្រប់ៗគ្នា . . . " ។

# សុន្ទរកថាព្រះពោធិវង្ស

"... អស់លោកគង់បានដឹងហើយថាមនុស្សយើងទោះបីចេះដឹងច្រើនអម្បាលម៉ានក៏ដោយ តែបើខ្វះអាចារសីលគឺកិរិយាមារយាទដ៏ថ្លៃថ្លាហើយ មុខជានឹងទប់ខ្លួនឲ្យឋិតនៅជាស្ថាពរឬនឹងកែខ្លួនឲ្យទៅជាអ្នកមានដំឡៃថ្លៃថ្នូរសមរម្យតាមចំណោះនោះពុំបានឡើយ នឹងនាំឲ្យអាប់ឱនថោកថយសាបរលាបជាងមនុស្សសាមញ្ញទៅទៀតក៏សឹងមានដែរ ... ។ ... បុគ្គលដែលនឹងតាំងខ្លួនជាមេជាបាត្រួតត្រាគ្រប់គ្រងវង្សត្រកូលពួកក្រុមឬសិស្សគណឲ្យបានសេចក្ដីសុខក្សេមក្សាន្តទូលំទូលាយទៅបាននោះ តោងអាស្រ័យធម៌ ៣ ប្រការគឺ ១- អាចារសីល = កិរិយាមារយាទល្អ;
២- បញ្ញា = សេចក្ដីដឹងកិច្ចការសព្វអន្លើ ព្រមទាំងវៃឆ្លៀវឆ្លាស;
៣- ពាហុសច្ចៈ= ការរៀនសូត្រចេះដឹងច្រើន ។ ...

# ព្រះរាជសុន្ទរកថា

លោកគ្រូ ! អស់លោក !

ក្នុងឱកាសប្រគេនព្រហ្មទាននេះ ខ្ញុំករុណា - ខ្ញុំមានសោមនស្សពន់ពេកណាស់ដោយបានមកជួយសរសើរព្រះសង្ឃជាសិស្សានុសិស្សដែលប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។

ខ្ញុំករុណា - ខ្ញុំបានដឹងថា ការរៀនយកសញ្ញាប័ត្រសាលាបរិយត្តិជាន់ខ្ពស់នេះ មិនមែនជាការងាយស្រួល គឺជាការខំអត់ធ្មត់សង្វាត ដ៏ខ្ជាប់ខ្ជួន

រៀនពបមកជាច្រើនឆ្នាំហើយ ទើបបានសម្រេចផល ។ ដូច្នេះ,ការប្រឡងបានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់នេះជាការគួរឲ្យសរសើរណាស់ ។

ខ្ញុំករុណា-ខ្ញុំសង្ឃឹមថា លោកដែលប្រឡងបានសញ្ញាប័ត្រ សាលាបា-លីជាន់ខ្ពស់ដែលជនទាំងឡាយតែងសំគាល់លោកជាបណ្ឌិតទៅអនាគត ដោយលោកមានចំណេះវិជ្ជាដ៏ប្រពៃ ដើម្បីនឹងយកវិជ្ជានោះធ្វើឲ្យបានផលប្រយោជន៍ទៅច្រើនឡើងថែមទៀតជាប្រយោជន៍ដល់ប្រទេសជាតិ ព្រមទាំងជាការតបស្នងសងគុណដល់ពួកពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយឧបត្ថម្ភលោករៀងមក ក្នុងការរៀនសូត្រនេះ នឹងយកព្រះទ័យទុកដាក់ណែនាំសិស្សានុសិស្ស នឹងឧបាសកឧបាសិកាក្នុងក្រុមលោករៀងរាល់ក្រុម ឲ្យបានចេះដឹងច្រើន នឹងប្រតិបត្តិកិរិយាឲ្យសមប្រកបតាមពុទ្ធសាសនាពាទ ជាប្រយោជន៍ខាងពុទ្ធចក្រ នឹងអាណាចក្រតទៅ ។

ពិធីប្រគេនព្រហ្មទាននេះ ជាការមួយយ៉ាងសំខាន់ នាំឲ្យបណ្ដាជនានុជនច្រើនធាប់បានស្គាល់សិស្សានុសិស្ស ដែលរៀនសូត្រមានល្បីកេរ្តិ៍ឈ្មោះ ហើយនាំសំរេចទឹកចិត្តសិស្សានុសិស្ស ដែលចាប់រៀនឡើងពីដើមឆ្នាំក្នុងថ្នាក់នីមួយ ៗ ឲ្យខំរៀនប្រាថ្នាចង់បានសញ្ញាប័ត្រផង ប្រាថ្នាចង់បានកេរ្តិ៍ឈ្មោះផង ។

ដូច្នេះ, ខ្ញុំករុណា - ខ្ញុំ សូមអរគុណដ៏ពន្លឹក ដល់អស់លោក - អ្នកដែលបានចំណាយបច្ច័យ ជាកំឡាំងក្នុងការរៀបចំធ្វើពិធីប្រគេនព្រហ្មទាននេះជាយ៉ាងអនេក ។

IMPRIMERIE ROYALE